**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបើក
## កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៤

**ថ្ងៃពុធ ៥រោច ខែកត្តិក ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨**

**ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤**

**នៅទីស្តីការគណៈរដ្ឋមន្ត្រី**

- សូមគោរពអង្គពិធីទាំងមូល
- ឯកឧត្តម លោកជំទាវ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋានរាជធានី ខេត្ត និងកាកបាទក្រហមកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!

ថ្ងៃនេះខ្ញុំពិតជាមានកិត្តិយស និងក្តីសប្បាយរីករាយ ដោយបានចូលរួមជាអធិបតីក្នុងការដឹកនាំ **"កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៤"**។ ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុត និងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានយកពេលវេលាដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គលើកទី២ សម្រាប់ឆ្នាំ២០២៤ នាពេលនេះ។

ជាមួយគ្នានេះ ខ្ញុំសូមគោរពថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅ ជូនចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែង និងការសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការជំរុញ និងចូលរួមអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាលកម្ពុជា រួមនឹងលិខិតជូនដំណឹងលេខ ២១៣ សជណ.សស របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដោយទទួលលទ្ធផលជាផ្លែផ្កា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា !**

ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងការកោតសរសើរ និងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាសមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ រួមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ដែលបានចូលរួមយ៉ាងសកម្មក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។ យើងទាំងអស់គ្នាគួរតែមានមោទនភាពចំពោះវឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផល ប្រកបដោយជោគជ័យ ដែលកម្ពុជាយើងទទួលបានកន្លងមកក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍។

គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការវិស័យសុខាភិបាល បានផ្តល់នូវសិទ្ធិ និងការទទួលខុសត្រូវពេញលេញ ដល់អាជ្ញារធរគ្រប់លំដាប់ថ្នាក់ ក្នុងការគ្រប់គ្រងមុខងារ និងធនធានសុខាភិបាលរបស់ខ្លួន ដើម្បីឆ្លើយតបជាពហុវិស័យ ចំពោះការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយចីរភាពនៅកម្ពុជា។ ក្នុងគោលបំណង បង្កើតបាននូវភាពម្ចាស់ការរបស់ខ្លួនលើវឌ្ឍនភាពនៃគុណវិស័យដោយការរៀបចំយន្តការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំផែនការយុទ្ធសាស្រ្ត និងការអនុវត្តសកម្មភាព រួមនឹងការតាមដាន វាយតម្លៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ផ្តោតលើ គោលដៅ៩៥-៩៥-៩៥ និងចំនួនប្រជាជនគន្លឹះដែលរកឃើញមានផ្ទុកមេរោគអេដស៍ រួមនឹងអត្រានៃការប្រើស្រោមអនាម័យ ហើយក៏ជាមគ្គុទេសក៏តម្រង់ផ្លូវមានរយៈពេលវែងមានលក្ខណៈគ្រប់ជ្រុងជ្រោយ គ្របដណ្តប់លើគ្រប់វិស័យ ដោយបានគោរពយ៉ាងខ្ជាប់ខ្ជួន ទៅនឹងផែនការយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក៏សូមវាយតម្លៃខ្ពស់ដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានជួយគាំទ្រគោលនយោបាយជាតិរបស់យើងដោយបានដាក់ចេញនូវនីតិវិធី សម្រាប់ប្រើប្រាស់ថវិការដ្ឋនៅថ្នាក់ក្រោមជាតិ និងផ្តល់ថវិកាសម្រាប់ការងារអេដស៍ ដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្នុងការចូលរួមអនុវត្តសកម្មភាពឆ្លើយតបនឹងជំងឺអេដស៍។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**!

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ធ្វើឡើងដើម្បីពិនិត្យមើលរួមគ្នានូវវឌ្ឍនភាព សមិទ្ធផល និងប្រសិទ្ធភាព ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់រយៈពេល៦ខែចុងឆ្នាំ២០២៤ និងធ្វើការប្រមូល ពិភាក្សាលើធាតុចូល រួមជាមួយនឹងអនុសាសន៍មួយចំនួន តាមរយៈការចូលរួមរបស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញាដែលមានវត្តមានក្នុងពេលនេះ។

តាមរបៀបវារៈកិច្ចប្រជុំ យើងនឹងមានបទបង្ហាញចំនួនពីរ រួមមាន ៖

ទី១-បទបង្ហាញសេចក្តីព្រាងវឌ្ឍនភាព នៃការអនុវត្តសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២៤ បង្ហាញជូនដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ទី២-បទបង្ហាញស្តីពីការសម្របសម្រួលផ្តល់កញ្ចប់សេវាសង្គម សម្រាប់ប្រជាជនគន្លឹះដើម្បីរួមចំណែកឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ បង្ហាញជូនដោយ៖

- **លោក កែវ អ៊ូលី** ប្រធាននាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃក្រសួងផែនការ

○ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករងបេឡាជាតិសន្តិសុខសង្គមនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

កិច្ចប្រជុំពេញអង្គនឹងធ្វើការពិភាក្សាផ្លាស់ប្តូរយោបល់ និងផ្តល់ធាតុចូលទៅលើបទបង្ហាញលើ។ បន្ទាប់មក យើងនឹងមានការពិភាក្សាអនុម័តសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២៤ សម្រាប់ជាទិសដៅអនុវត្តបន្តក្នុងឆមាសទី១ ឆ្នាំ២០២៥។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**!

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមទាញអារម្មណ៍កិច្ចប្រជុំពេញអង្គថា យើងបាន និងកំពុងកសាងបាននូវចីរភាព នៃការឆ្លើយតបជាពហុវិស័យ ដោយការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន ជាពិសេសបណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជនគន្លឹះ។ យើងបានពង្រឹងការអនុវត្តនូវគោលការណ៍បីមួយ ស្ថាប័នដឹកនាំគ្រប់គ្រង និងសម្របសម្រួលតែមួយទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិតែមួយ និងមានប្រព័ន្ធតាមដាន និងវាយតម្លៃជាតិតែមួយប្រកបដោយប្រសិទ្ធភាព។

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលដែលទទួលបានពីកិច្ចប្រជុំនេះ ពិតជាមានសារៈសំខាន់ផ្តល់ជូនក្រុមការងារបច្ចេកទេស អាចយកទៅបន្តអនុវត្តឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីឆ្ពោះទៅសម្រេចបាននូវគោលដៅដែលបានកំណត់ក្នុងគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨។

ដើម្បីទុកពេលវេលាឱ្យបានច្រើនដល់ការធ្វើបទបង្ហាញ និងការពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ពីបណ្តាសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកកិច្ចប្រជុំនាពេលនេះ និងសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន និងប្រាជ្ញាវាងវៃ ដើម្បីចូលរួមពិភាក្សាឱ្យទទួលបានជោគជ័យទៅតាមកម្មវត្ថុដែលបានគ្រោងទុក និងសូមប្រកាសបើក “**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២៤** ” ចាប់ពីពេលនេះតទៅ។

**សូមអរគុណ**!